00495838

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 12 / 04 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លេខ / N°: D344/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi
Kingdom of Cambodia
Nation Religion King

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / 04 / 2010
ម៉ោង (Time/Heure): 10:06
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**Case File No: 002/19-09-2007-ECCC-OCIJ**

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**

**Bureau des co-juges d'instruction**

ចំពោះមុខ ៖ **ចៅក្រម យូ ប៊ុនឡេង**

**ចៅក្រម Marcel LEMONDE**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០១០**

ភាសា ៖ **ខ្មែរ/អង់គ្លេស**

ចំណាត់ថ្នាក់ឯកសារ ៖ **សាធារណៈ**

---

# ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹងខ្សែភាពយន្ត "សត្រូវរបស់ប្រជាជន"

---

**<u>សហព្រះរាជអាជ្ញា</u>**

លោកស្រី ជា លាង

លោក Andrew CAYLEY

**<u>ជនត្រូវចោទ</u>**

នួន ជា

ខៀវ សំផន

អៀង សារី

កាំង ហ្គេកអ៊ាវ ហៅ ឌុច

អៀង ធីរិទ្ធ

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

នី ច័ន្ទឌី
ឡោ ជុនធី
គង់ ពិសី
ហុង គីមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
ស៊ិន សុវន
ជេត វណ្ណលី
ពេជ អង្គ
Silke STUDZINSKY
Françoise GAUTRY
Phillipe CANONNE
Elizabeth Rabesandratana
Mahdev MOHAN
Olivier BAHOUGNE
David BLACKMAN
Martine JACQUIN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BAUDOIN
Lyma Thuy Nguyen
Marie Guiraud
Laure DESFORGES
Christine MARTINEAU
Pascal AUBOIN
Isabelle DURAND

**<u>មេធាវីការពារក្តី</u>**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅស៊ាង
Diana ELLIS
ស សុវាន
Jacques VERGÈS
ការ សាវុត្ថ
François ROUX
Marie-Paule CANIZARÈS

00495839

002/19-09-2007-ECCC-OCIJ លេខ / No: D334/1

យើង **យូ ប៊ុនឡេង** និង **Marcel LEMONDE** (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញការស៊ើបសួរ លើឈ្មោះ **នួន ជា** និង **ជនដទៃ** ដែលត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យចំពោះ **បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ បទប្រល័យពូជសាសន៍ ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការវាយប្រហារលើសាសនា** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២០៩ មាត្រា ២១០ មាត្រា ៥០០ មាត្រា ៥០១ មាត្រា ៥០៣ ដល់ មាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦

បានឃើញវិធាន ៥៥ និង វិធាន ៦៦ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញសំណើរបស់សហព្រះរាជអាជ្ញា សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១០ ("សំណើសុំ"- D344)

## សំណើសុំរបស់សហព្រះរាជអាជ្ញា

១. នៅថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១០ សហព្រះរាជអាជ្ញា បានស្នើចំពោះសហចៅក្រមស៊ើបអង្កេត ("សចស") ដើម្បីទទួលបានច្បាប់ថតចម្លងខ្សែភាពយន្តរឿង *"សត្រូវរបស់ប្រជាជន" (Enemies of the People)* និងបទសម្ភាសន៍ដែលបានថតជាសម្លេង និងរូបភាពវីដេអូនានា សម្រាប់ប្រើប្រាស់ក្នុងការបង្កើតខ្សែភាពយន្តនេះ ព្រមទាំងបទសម្ភាសន៍ជាមួយ នួនជា ទាក់ទិននឹងការជាប់ពាក់ព័ន្ធរបស់គាត់ចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិប-តេយ្យ រួចហើយដាក់ច្បាប់ថតចម្លងទាំងនេះទៅក្នុងសំណុំរឿង ០០២។ សហព្រះរាជអាជ្ញា បានស្នើឲ្យសហចៅក្រមស៊ើបអង្កេតធ្វើទំនាក់ទំនងជាមួយលោក ថេត សម្បត្តិ ចាងហ្វាងខ្សែភាពយន្ត និងលោក Rob LEMKIN ផលិតករខ្សែភាពយន្តនេះ និង/ឬ បុគ្គលផ្សេងទៀត ដើម្បីអាចទទួល



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ
ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

បានច្បាប់ថតចម្លងខ្សែភាពយន្តនេះ។ លើសពីនេះទៀត សហព្រះរាជអាជ្ញា បានស្នើឲ្យ ស.ច.ស ធ្វើឯកសារនៃកិច្ចខិតខំប្រឹងប្រែង ក្នុងការទទួលបានឯកសារនេះ និងប្រមូលព័ត៌មាន ស្តីពីបណ្តាញនៃការរក្សាទុក នៃរាល់ឯកសារទាំងអស់ដែលទទួលបាន។

២. ដូចមាននៅក្នុងឧបសម្ព័ន្ធនៃសំណើសុំរបស់ខ្លួន សហព្រះរាជអាជ្ញា បានភ្ជាប់នូវអត្ថបទសារព័ត៌មានមួយច្បាប់ ដែលមានចំណងជើង *"Khmer Rouge killing machine explored at Sundance"* ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១០ ដែលបោះពុម្ពផ្សាយដោយ Agence France Press ដែលបានរៀបរាប់ពីខ្លឹមសាររបស់ខ្សែភាពយន្ត និងជាពិសេសពីការប្រកាសរបស់ នួន ជា នៅក្នុងនោះ[1]។

**សេចក្តីសង្ខេបនៃអង្គហេតុ**

៣. ទោះបីជាខ្លឹមសារនៃខ្សែភាពយន្ត និងសេចក្តីប្រកាសដែលធ្វើឡើងដោយ នួន ជា នៅក្នុងខ្សែភាពយន្តនោះ ត្រូវបានគិតថាវាកម្រិតស្រាលជាងបើប្រៀបធៀបទៅនឹងភស្តុតាងដែលប្រមូលបានដោយផ្ទាល់ដោយ ស.ច.ស នៅក្នុងអំឡុងពេលនៃការស៊ើបសួរ ក៏ដោយក៏ ស.ច.ស យល់ស្របជាមួយនឹងអំណះអំណាងរបស់សហព្រះរាជអាជ្ញា និងដោយផ្អែកលើការពិពណ៌នារបស់ប្រព័ន្ធសារព័ត៌មាន ពីខ្លឹមសារនៃខ្សែភាពយន្ត និងជាពិសេសសេចក្តីប្រកាសដែលធ្វើឡើងដោយជនត្រូវចោទ នួន ជា យល់ឃើញថា ខ្សែភាពយន្តនេះ អាចមានព័ត៌មានដែលអាចមានផលប្រយោជន៍ដល់ការបង្កើតការពិតនៅក្នុងសំណុំរឿង ០០២ ហេតុដូចនេះ វាគួរត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង។ ដូច្នេះ ស.ច.ស យល់ព្រមទទួលសំណើសុំនេះ។

៤. អាស្រ័យហេតុនេះ នៅថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១០ សចស បានសរសេរលិខិតមួយច្បាប់ទៅ Robert Lemkin[2] ដើម្បីស្នើសុំខ្សែភាពយន្តថតចម្លងមួយច្បាប់ ក្នុងគោលបំណងនៃការស៊ើបសួរលើ នួន ជា[3]។

---

[1] ច្បាប់ចម្លងជាសាធារណៈនៃអត្ថបទនេះ អាចរកបានតាមរយៈ http://www.rnw.nl/international-justice/article/khmer-rouge-killing-machine-exposed-sundance និង http://www.france24.com/en/20100128-khmer-rouge-killing-machine-explored-sundance

[2] លិខិតដែលបានចុះហត្ថលេខារួចហើយ ត្រូវបានថតស្កេន និងបានផ្ញើទៅអ៊ីម៉ែលរបស់ Robert Lemkin តាមរយៈក្រុមហ៊ុនផលិតភាពយន្តរបស់គាត់ដែលមានទីតាំងនៅ ក្រុង Oxford ចក្រភពអង់គ្លេស។

៥. Robert Lemkin បានឆ្លើយតបតាមរយៈអ៊ីម៉ែល នៅថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ ២០១០ បញ្ជាក់ថា គាត់បានពិភាក្សាពីសំណើនេះ ជាមួយ ថេត សម្បត្តិ និងដោយហេតុថា ខ្សែភាពយន្តនេះ មិនទាន់បាន "ចាក់បញ្ចាំងជាទូទៅ" នៅឡើយនោះ ពួកគេមិនអាចផ្តល់ជូននូវច្បាប់ថតចម្លងបានទេ ប៉ុន្តែពួកគេអាចរៀបចំបញ្ចាំងខ្សែភាពយន្តនេះជាសាធារណៈបាន ហើយ "មន្ត្រីរបស់តុលាការណាក៏អាចមកមើលខ្សែភាពយន្តនេះបាន"[4]។

៦. ស.ច.ស បានឆ្លើយតបទៅ Robert Lemkin វិញតាមរយៈលិខិតចុះថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ ២០១០[5] ដោយបានផ្តល់នូវការបញ្ជាក់ច្បាស់ជាងមុនពីក្របខណ្ឌច្បាប់ដែលគ្រប់គ្រងការស៊ើបសួរនៅ អ.វ.ត.ក ដោយបានសង្កត់ធ្ងន់ថា ការស៊ើបសួរឈានជិតដល់ទីបញ្ចប់ហើយ និងបានពន្យល់ទៀតថា ប្រការដែលមន្ត្រីរបស់តុលាការណាម្នាក់ចូលរួមទស្សនាខ្សែភាពយន្ត នឹងមិនផ្តល់តម្លៃជាភស្តុតាងណាមួយទេ និងថា វានឹងមិនមានលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់សម្រាប់យកមកពិចារណាទៅលើខ្លឹមសារនៃខ្សែភាពយន្តនៅក្នុងដំណើរការនៃកិច្ចស៊ើបសួរលើ នួន ជា ទេ។

៧. ដោយសារមិនមានចម្លើយតបណាមួយចំពោះលិខិតនេះ ពីសំណាក់លោក Robert Lemkin ការិយាល័យសហចៅក្រមស៊ើបអង្កេតបានធ្វើការទំនាក់ទំនងតាមទូរស័ព្ទនៅក្នុងខែមីនា ឆ្នាំ ២០១០។ ក្នុងពេលសន្ទនាតាមទូរស័ព្ទនោះ លោក Robert Lemkin បានបញ្ជាក់ឡើងវិញថា គាត់មិនទាន់ត្រៀមខ្លួនក្នុងការផ្តល់ខ្សែភាពយន្តនោះមកឲ្យតុលាការ មុននឹងការចេញផ្សាយខ្សែភាពយន្តនេះដល់សាធារណជននោះទេ ហើយចំពោះការធានាលើការសម្ងាត់ និងការប្រើប្រាស់តាមផ្លូវច្បាប់ ដែលនឹងត្រូវផ្តល់ដោយសហចៅក្រមស៊ើបអង្កេតក៏មិនទាន់មានលក្ខណៈគ្រប់គ្រាន់នោះដែរ និងបន្តថា មុនពេលនឹងមានការចេញផ្សាយដល់សាធារណជន គាត់បានត្រៀមខ្លួនចំពោះតែការចាក់ផ្សាយសម្រាប់តែបុគ្គលិកតុលាការតែប៉ុណ្ណោះ។

---

[3] ឧបសម្ព័ន្ធ ១ នៃដីកានេះ។

[4] ឧបសម្ព័ន្ធ ២ នៃដីកានេះ។

[5] ឧបសម្ព័ន្ធ ៣ នៃដីកានេះ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ
ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00495842



## សំអាងហេតុនៃសេចក្ដីសម្រេច

៨. នៅក្នុងខែ មករា ឆ្នាំ ២០១០ លោក Robert Lemkin បានប្រកាសជាសាធារណៈថា៖ *"ខ្សែភាពយន្តនេះនឹងត្រូវប្រើប្រាស់ដោយតុលាការ និងនឹងត្រូវផ្តល់ឱ្យតុលាការ។ យើងមានមោទនភាពចំពោះទង្វើនេះណាស់។"*[6] សហចៅក្រមស៊ើបអង្កេតយល់ឃើញថា វាជារឿងគួរឱ្យសោកស្តាយណាស់ដែលថា ទោះបីជាការអធិប្បាយនេះបានធ្វើឡើងទៅកាន់បណ្តាញសារព័ត៌មានអន្តរជាតិក្តី ក៏អ្នកផលិតខ្សែភាពយន្តរូបនេះបានបង្ហាញនូវអាកប្បកិរិយាមិនចង់សហការសោះ គឺបន្ទាប់ពីតុលាការបានព្យាយាមធ្វើការទាក់ទងជាផ្លូវការក៏ដោយ និងទោះបីជាតុលាការផ្តល់នូវការធានាតាមផ្លូវច្បាប់លើទិដ្ឋភាពមួយចំនួនទៀតផងដែរ។

៩. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការរង់ចាំរហូតដល់មានការចេញផ្សាយជាសាធារណៈនៃខ្សែភាពយន្តនេះ គឺមិនដូចគ្នានឹងការណ៍ដែលផលិតករយល់ព្រមប្រគល់ខ្សែភាពយន្តនេះមកឱ្យតុលាការនោះទេ ព្រោះបើត្រូវរង់ចាំរហូតដល់ពេលនោះមែន គឺតុលាការអាចទទួលបាននូវខ្សែភាពយន្តនោះ ដោយមិនបាច់មានការជួយឧបត្ថម្ភគាំទ្ររបស់ផលិតកររូបនោះឡើយ។

១០. សហចៅក្រមស៊ើបអង្កេតធ្វើការបញ្ជាក់ថា ការចូលរួមការចាក់ផ្សាយជាសាធារណៈមិនអាចផ្តល់ឱ្យខ្សែភាពយន្តនេះនូវតម្លៃជាភស្តុតាង និងមិនមែនជាការដាក់ខ្សែភាពយន្តនេះចូលក្នុងសំណុំរឿង ដែលមានអនុភាពគតិយុត្តសម្រាប់ប្រើប្រាស់ក្នុងការតាក់តែងដីកាដំណោះស្រាយនោះឡើយ (ដែលនេះវាជារឿងចាំបាច់)។

១១. សហចៅក្រមស៊ើបអង្កេតយកចិត្តទុកដាក់ចំពោះលទ្ធភាពនៃការទទួលបានខ្សែភាពយន្ត *"Enemies of the People"* និង ខ្សែវីដេអូ និងកាសែតសម្លេងដែលថតការសម្ភាសន៍ នៅពីក្រោយការផលិតខ្សែភាពយន្តនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយពិនិត្យទៅលើពេលវេលាដែលត្រូវប្រើប្រាស់ និងការលំបាកនានា ជុំវិញការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសអន្តរជាតិ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា វាមិនជាការចាំបាច់ និងត្រឹមត្រូវនោះទេដែលត្រូវប្រើប្រាស់ពេលវេលា និងធនធាននៅក្នុងការងារនេះ ជាពិសេស នៅក្នុងកាលៈទេសៈណាក៏ដោយ ប្រសិនបើជនត្រូវចោទត្រូវបានចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះ សហព្រះរាជអាជ្ញានៅតែអាច

[6] អត្ថបទរបស់ Agence France Press ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១០ ដែលយោងខាងលើ (លេខយោងទី ១)។

ស្វែងរកខ្សែភាពយន្តនោះ ដើម្បីដាក់បញ្ចូលក្នុងសំណុំរឿងនៅក្នុងដំណាក់កាលជំនុំជម្រះបានរហូត (ពេលនោះយើងអាចសន្មតថា ខ្សែភាពយន្តនេះនឹងចេញផ្សាយជាសាធារណៈរួចហើយ)។

**អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេត សម្រេច**

- **ទទួលយក**សំណើសុំរបស់សហព្រះរាជអាជ្ញា។
- **ជូនដំណឹង**ដល់សហព្រះរាជអាជ្ញាអំពីលទ្ធផលការងាររបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងបញ្ហានេះ ដូចមានរៀបរាប់នៅក្នុងដីកានេះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១០

**សហចៅក្រមស៊ើបអង្កេត**
**Co-Investigating Judges**
**Co-juges d'instruction**

**Marcel LEMONDE**

យូ ប៊ុនឡេង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ
ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។